**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

# សេចក្តីប្រកាសព័ត៌មាន

កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ កន្លងទៅ, រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៦ បានសម្រេចអនុម័តតាមសម្លេងលើសពីពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល លើសេចក្តីព្រាងច្បាប់ធម្មនុញ្ញ ដែលជាសំណើធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា សំដៅបំពេញចន្លោះខ្វះខាតនៃរដ្ឋធម្មនុញ្ញ និងធានាការពារឧត្តមប្រយោជន៍របស់ជាតិ និងប្រជាជនកម្ពុជា ជាពិសេសការធានាឱ្យស្ថាប័នរដ្ឋ មានកិច្ចដំណើរការប្រព្រឹត្តទៅដោយរលូន មិនជាប់គាំង ប្រកបដោយនិរន្តរភាពនៅគ្រប់កាលៈទេសៈ។ កន្លងទៅនេះ, តំណាងរាជរដ្ឋាភិបាល បានបកស្រាយបំភ្លឺអំពីខ្លឹមសារ និងគោលបំណងនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ នេះ ហើយក៏បានឆ្លើយតប ដើម្បីបំភ្លឺទៅនឹងកង្វល់នានា ឬការលើកឡើងនានា ឬការយល់ដឹងនានា ដែលមិនមានមូលដ្ឋានច្បាស់លាស់ និងដែលមិនមានលក្ខណៈត្រឹមត្រូវ ជុំវិញសំណើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ នេះ។

ប៉ុន្តែ ទោះបីជាយ៉ាងនេះក្តី ដើម្បីធានាឱ្យបាននូវការយល់ដឹងកាន់តែច្បាស់អំពីខ្លឹមសារពិតប្រាកដ និងគោលបំណងពិតប្រាកដនៃការធ្វើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ក្រសួងយុត្តិធម៌ មានកិត្តិយសសូមគោរពអញ្ជើញគណបក្សនយោបាយ ឬអង្គការសង្គមស៊ីវិលណា ដែលយល់ថា ឬអះអាងថា ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ នេះ ប៉ះពាល់ដល់ ***ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស*** ឬ***របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ*** ឬ***របបសភានិយម*** នៅកម្ពុជា ចូលរួមជំនួបពិភាក្សា ដើម្បីក្រសួងយុត្តិធម៌ អាចពន្យល់ និងបកស្រាយបំភ្លឺដោយផ្ទាល់បន្ថែមទៀត ជាពិសេស ដើម្បីជម្រះចោលនូវកង្វល់មិនត្រឹមត្រូវនានាជុំវិញការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ នេះ។

ជំនួបនេះនឹងត្រូវធ្វើឡើងនៅ**ទីស្តីការក្រសួងយុត្តិធម៌ នៅរសៀលថ្ងៃទី២, ទី៣ និងទី៤ ខែសីហា ឆ្នាំ២០២២ ចាប់ពីវេលាម៉ោង ១៤:៣០ នាទី តទៅ** អាស្រ័យទៅតាមសំណើ និងពេលវេលារបស់គណបក្សនយោបាយ ឬអង្គការសង្គមស៊ីវិល។ ចំពោះគណបក្សនយោបាយ ឬអង្គការសង្គមស៊ីវិល ដែលមានបំណងជួបក្រសួងយុត្តិធម៌ តាមការអញ្ជើញនេះ សូមមេត្តាទាក់ទង**ឱ្យបានមុនថ្ងៃជួបមួយថ្ងៃ** ដើម្បីចុះឈ្មោះ និងកំណត់កាលបរិច្ឆេទជួប តាមរយៈ៖ (១)-លោក **ទីវ សុផុណ្ណារតន៍** ០៦១ ៤៩៩ ៩៦៤ ឬ (២)-កញ្ញា **ឈួន មរកត** ០៧០ ៨៤០ ៥៨៥។

ដើម្បីធានាបានតម្លាភាពនៅក្នុងជំនួបនេះ, ក្រសួងយុត្តិធម៌ សូមអញ្ជើញអ្នកសារព័ត៌មាន មេត្តាតាមដាន និងយកព័ត៌មានដោយផ្ទាល់ពីជំនួបនេះ ទៅតាមកាលបរិច្ឆេទ ដែលក្រសួងយុត្តិធម៌ នឹងជម្រាបជូនតាមក្រោយ បន្ទាប់ពីទទួលបានសំណើពីសំណាក់គណបក្សនយោបាយ ឬអង្គការសង្គមស៊ីវិល ដែលឆ្លើយតបទៅនឹងការអញ្ជើញជាសាធារណៈរបស់ក្រសួងយុត្តិធម៌។

អាស្រ័យហេតុនេះ សូមបណ្តាគណបក្សនយោបាយ, អង្គការសង្គមស៊ីវិល និងអ្នកសារព័ត៌មាន មេត្តាជ្រាបជាព័ត៌មាន តាមការគួរ។

ថ្ងៃសុក្រ ១កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២

*__បញ្ជាក់៖__ សូមធ្វើតេស្តរហ័សរកមេរោគកូវីដ-១៩ ដោយខ្លួនឯង មុននឹងចូលរួមក្នុងជំនួបនេះ។*

មហាវិថីសម្តេចសុធារស.ខណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ ៖ 023 216 322, 023 217 841, 023 212 693